អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

*សេចក្តីណែនាំអនុវត្ត ០២/២០០៧/វ០១*

# ការចូលរួមនៃជនរងគ្រោះ

**គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) **ដោយ**

**ពិចារណាទៅលើ** កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានចុះហត្ថលេខាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ (ដែលបន្ទាប់ពីនេះ ហៅកាត់ខ្លីថា "**កិច្ចព្រមព្រៀង**")។

**ពិចារណាទៅលើ** ច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងវិសោធនកម្មដែលត្រូវបានអនុម័តប្រកាសអោយប្រើប្រាស់នៅថ្ងៃទី ២៧ តុលា ២០០៤ (ដែលបន្ទាប់ពីនេះ ហៅកាត់ខ្លីថា "**ច្បាប់អ.វ.ត.ក**")។

**ពិចារណាទៅលើ** វិធានផ្ទៃក្នុងនៃអ.វ.ត.ក ដែលបានអនុម័តដោយកិច្ចប្រជុំពេញអង្គចៅក្រមនៅថ្ងៃទី១២ ខែមិថុនា ២០០៧ និងត្រូវបានចុះហត្ថលេខាអោយចូលជាធរមាននៅថ្ងៃទី ១៨ មិថុនា ២០០៧។

**អនុលោម**ទៅតាមវិធាន ២០(៣)នៃវិធានផ្ទៃក្នុងអ.វ.ត.ក ដែលចែងអំពីគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង ក្នុងការធ្វើការអនុម័តលើសេចក្តីណែនាំអនុវត្តដែលទាក់ទងទៅនឹងដំណើរការនានានៃ អ.វ.ត.ក ហើយដែលត្រូវពិនិត្យឡើងវិញដោយកិច្ចប្រជុំពេញអង្គនៅក្នុងកិច្ចប្រជុំពេញអង្គនាពេលបន្តបន្ទាប់ ។

**តាមន័យដូចខាងលើនេះ សម្រេចចេញ**សេចក្តីណែនាំអនុវត្តអំពីការចូលរួមនៃជនរងគ្រោះ (ដែលបន្ទាប់ពីនេះហៅកាត់ខ្លីថា"**សេចក្តីណែនាំអនុវត្ត ០២/២០០៧/វ០១**")

## មាត្រា ១. បទប្បញ្ញត្តិទូទៅ

១.១ ជាការបន្ថែមទៅនឹងការចាត់ទុកជាសាក្សី ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចចូលរួមដោយសកម្មក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) តាមរយៈការដាក់ពាក្យបណ្តឹងទៅសហព្រះរាជអាជ្ញា ដូចមានចែងពិស្តារក្នុងមាត្រា ២ ខាងក្រោម ឬ ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅសហចៅក្រមស៊ើបអង្កេត ឬ នៅអង្គជំនុំ-ជម្រះសាលាដំបូង ដូចមានចែងពិស្តារនៅក្នុងមាត្រា ៣ ខាងក្រោម ។

១.២ អង្គភាពជនរងគ្រោះនៃអ.វ.ត.ក គឺជាកន្លែងទាក់ទងតែមួយគត់សំរាប់ជនរងគ្រោះទាំងអស់ ឬតំណាងរបស់ពួកគេ ក្នុងការបំពេញបែបបទ សំរាប់ចូលរួមនៅក្នុងដំណើរការជំនុំជម្រះ។ អង្គភាពជនរងគ្រោះអាចទាក់ទងបានដោយផ្ទាល់សំរាប់រាល់ព័ត៌មាន និង ការគាំទ្រទាក់ទងទៅនឹងការចូលរួមរបស់ជនរងគ្រោះតាមអាសយដ្ឋានដូចខាងក្រោម៖

អង្គភាពជនរងគ្រោះនៃ អ.វ.ត.ក
ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ: www.eccc.gov.kh
លេខទូរស័ព្ទ: ៨៥៥-២៣-២១៩-៨១៤
អាស័យដ្ឋានអ៊ីម៉ែល: victimsunit@eccc.gov.kh

**មាត្រា ២.នីតិវិធី និង ទំរង់បែបបទនៃការដាក់ពាក្យប្តឹងទៅការិយាល័យសហព្រះរាជអាជ្ញា**

២.១ សហព្រះរាជអាជ្ញាទទួលខុសត្រូវក្នុងការពិចារណាទៅលើរាល់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរ ឬព័ត៌មានទាំងឡាយណា អំពីការចោទប្រកាន់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ។

២.២ ជនរងគ្រោះនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ អាចដាក់ពាក្យបណ្តឹងទៅអង្គភាពជនរងគ្រោះដែលជាអ្នកបញ្ជូនមកសហព្រះរាជអាជ្ញា សំរាប់ធ្វើចំណាត់ការ ។ សមាគមជនរងគ្រោះ ឬមេធាវីជនរងគ្រោះអាចដាក់ពាក្យប្តឹង ក្នុងនាមសមាជិកសមាគមនោះ ឬក្នុងនាមកូនក្តីរបស់ខ្លួនបាន។

២.៣ អ្នកប្តឹងត្រូវផ្តល់ព័ត៌មានដូចខាងក្រោម:
ក. អត្តសញ្ញាណរបស់អ្នកប្តឹង
ខ.កម្មវត្ថុនៃបណ្តឹង
គ.សេចក្តីសង្ខេបនៃ បទល្មើសព្រហ្មទណ្ឌ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។
ឃ.ក្រៅពីនេះ ប្រសិនបើមាន ពាក្យប្តឹងត្រូវមាន
- ព័ត៌មានពិស្តារអំពីសាក្សីសំខាន់ៗ
- ភស្តុតាងទាំងឡាយដែលអ្នកប្តឹងមាន និង
-ការបង្ហាញអំពីគោលបំណងរបស់អ្នកប្តឹងថានឹងចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលការចាប់ផ្តើមការស៊ើបអង្កេតចំពោះសំណុំរឿងនោះ ។

២.៤ ពាក្យប្តឹងត្រូវធ្វើតាមទំរង់បែបបទស្នើចូលរួមរបស់ជនរងគ្រោះដូចមាននៅក្នុង (**ឧបសម្ព័ន្ធ “ក”**)។ ពាក្យបណ្តឹងត្រូវបញ្ជូន ឬ ផ្ញើមកអង្គភាពជនរងគ្រោះដូចមានអាសយដ្ឋាននៅក្នុងមាត្រា១.២ ខាងលើ។

២.៥ អង្គភាពជនរងគ្រោះអាចជួយអ្នកប្តឹងក្នុងការបំពេញពាក្យប្តឹងរបស់ពួកគេ ។

២.៦ អង្គភាពជនរងគ្រោះត្រូវបញ្ជូនរាល់ពាក្យប្តឹងទៅការិយាល័យសហព្រះរាជអាជ្ញា ។ ពាក្យប្តឹងទាំងនោះនឹងត្រូវចុះក្នុងបញ្ជី ដែលគ្រប់គ្រងដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអាចស្នើសុំអោយអង្គភាពជនរងគ្រោះ ជួយក្នុងការផ្តល់ការជូនដំណឹងទៅអ្នកប្តឹងវិញ ។

២.៧ ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក ពាក្យប្តឹងទាំងនោះមិនអាចជាប្រភពផ្តើមធ្វើការចោទប្រកាន់ជាស្វ័យប្រវត្តិអំពីបទឧក្រិដ្ឋបានទេ ហើយសហព្រះរាជអាជ្ញាត្រូវធ្វើការសំរេចដោយឆន្ទានុសិទ្ធិ ថាតើត្រូវតំកល់បណ្តឹងទុកឥតចាត់ការ ឬ បញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេតបឋមកំពុងដំណើរការ ឬ បើកការស៊ើបអង្កេតបឋម ឬ បញ្ចូលពាក្យប្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការសំរេចទៅអ្នកប្តឹងជាបន្ទាន់ តាមដែលអាចធ្វើទៅបាន និង ក្នុងគ្រប់ករណីទាំងអស់ មិនត្រូវអោយលើសពីពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃចុះពាក្យប្តឹង ។

២.៨ ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក សហព្រះរាជអាជ្ញាអាចកែប្រែការសំរេចចិត្តរបស់ខ្លួនគ្រប់ពេលបាន ក្នុងករណីនេះត្រូវជូនដំណឹងទៅអ្នកប្តឹងពីសេចក្តីសំរេចនេះអោយបានឆាប់តាមដែលអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ មិនត្រូវអោយលើសរយះពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេច ។

២.៩ អង្គភាពជនរងគ្រោះ និង សហព្រះរាជអាជ្ញាត្រូវធានាអំពីភាពសំងាត់នៃរាល់ពាក្យប្តឹងដែលដាក់នៅ អ.វ.ត.ក។

## មាត្រា ៣.ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៣.១ ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក អាចចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនៃឧក្រិដ្ឋកម្មនោះ ។

៣.២ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ដើម្បីអាចអោយចាត់ទុកថាជាជនរងគ្រោះ ដែលស្ថិតនៅក្នុងគោលបំណងរបស់ អ.វ.ត.ក ។

ក.អ្នកប្តឹងត្រូវជារូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មណា

មួយស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក ។

ខ.ដើម្បីត្រូវបានកំណត់ថាបានរងព្យសនកម្ម អ្នកប្តឹងត្រូវបង្ហាញ៖

-ការខូតខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និង

-ជាផលលំបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនោះ ជាព្យសនកម្មដោយផ្ទាល់ខ្លួន និង បានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន។

គ.ការខូតខាតផ្លូវចិត្ត អាចគិតទាំងការស្លាប់ញាតិសន្តាន ដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ ។

ឃ.ជនរងគ្រោះទាំងអស់ ដែលបានបំពេញលក្ខណៈវិនិច្ឆ័យទាំងអស់នេះ មានសិទ្ធិដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានការរើសអើងចំពោះលក្ខណៈវិនិច្ឆ័យដូចជាលំនៅដ្ឋានបច្ចុប្បន្ន ឬសញ្ជាតិឡើយ។

៣.៣ ជនរងគ្រោះអាចដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែនៅពេលដែលសំណុំរឿងស្ថិតនៅក្នុងកិច្ចស៊ើបអង្កេត ដោយសហចៅក្រមស៊ើបអង្កេត និង រហូតដល់ពេលចាប់ផ្តើមនៃដំណើរការនីតិវិធីនៃសំណុំរឿងនោះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៣.៤ អង្គភាពជនរងគ្រោះអាចជួយគាំទ្រអ្នកដាក់ពាក្យប្តឹងក្នុងការបំពេញបែបបទ និង បញ្ជូនបែបបទពាក្យសុំនោះទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំសាលាដំបូង តាមករណីសមស្រប តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង។

៣.៥ រាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានព័ត៌មានដូចខាងក្រោមៈ

ក.ព័ត៌មានពិស្តារដែលអាចអោយធ្វើការបញ្ជាក់ថា អ្នកដាក់ពាក្យបំពេញលក្ខខណ្ឌជាជនរងគ្រោះ

ខ.បទល្មើសព្រហ្មទណ្ឌដែលបានចោទប្រកាន់

គ.លំនៅដ្ឋានរបស់ជនរងគ្រោះ ការិយាល័យសមាគមជនរងគ្រោះ ដែលបានចុះបញ្ជីដែលជនរង-គ្រោះជាសមាជិកឬ អាសយដ្ឋានរបស់មេធាវី ទៅតាមករណីសមស្រប ដែលអាចប្រើប្រាស់សំរាប់ការជូនដំណឹង ។ នៅពេលដែលអាសយដ្ឋាននោះនៅក្រៅប្រទេសកម្ពុជា អ្នកដាក់ពាក្យស្នើសុំ ឬតំណាងត្រូវផ្តល់អាសយដ្ឋាននៅក្នុងប្រទេសកម្ពុជា ដែលជាទូទៅអាសយដ្ឋាននោះ គឺជាអាសយ-ដ្ឋានរបស់អ្នកតំណាងនៃភាគីនៃដើមបណ្តឹងរដ្ឋប្បវេណី ។

ង.អ្នកដែលដាក់ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវភស្តុតាងដែលបញ្ជាក់អំពីព្យសនកម្មណាមួយដែលខ្លួនទទួលរង ឬ ភស្តុតាងដែលចង់បង្ហាញអំពីពិរុទ្ធភាពរបស់ចារី និង ជនសមគំនិតដែលត្រូវចោទ។

៣.៦ ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបានដោយបំពេញបែបបទសំរាប់ជនរងគ្រោះ

ស្នើសុំចូលរួម(**ឧបសម្ពន្ធ័ “ក”**) ។ នៅពេលដែលពាក្យស្នើសុំបំពេញចប់សព្វគ្រប់ហើយ ត្រូវបញ្ជូនទៅអង្គភាពជនរងគ្រោះ ។

៣.៧ ពាក្យស្នើសុំដែលបានបំពេញហើយ អង្គភាពជនរងគ្រោះ ត្រូវបញ្ជូនទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះសាលាដំបូង តាមករណីសមស្រប តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ជាមួយនឹងព័ត៌មានសំខាន់ៗទាក់ទងនឹងអ្នកតំណាងរួម ។ នៅពេលដែលអង្គបុរេជំនុំជម្រះទទួលបានពាក្យស្នើសុំ ឬ បណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងទៅអង្គបុរេជំនុំជម្រះ នូវពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីណាមួយ បន្ទាប់ពីបានធ្វើការវាយតំលៃជាបឋម លើពាក្យស្នើសុំហើយ។

៣.៨ តាមករណីសមស្រប សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះសាលាដំបូង ត្រូវសំរេចអំពីការទទួលយកបាន ឬ មិនអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ សេចក្តីសម្រេចនេះបើកផ្លូវ អោយមានបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬ បណ្តឹងសារទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ទៅតាមដំណាក់កាលសមស្រប ។

៣.៩ នៅពេលដែលជនរងគ្រោះ ត្រូវបានអនុញ្ញាតអោយចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីហើយ អង្គ-ភាពជនរងគ្រោះមិនមានតួនាទីនៅក្នុងដំណើរការនីតិវិធីទៀតទេ ។ ប៉ុន្តែអង្គភាពនេះក៏អាចនៅផ្តល់ការគាំទ្រក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹងការចូលរួមសមាជិកសមាគមជនរងគ្រោះ ការការពារតាមផ្លូវច្បាប់ និង វិធានការការពារ ។

## មាត្រា ៤.ការតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណីដោយមេធាវី

៤.១ រាល់ជនរងគ្រោះដែលចូលរួមក្នុងដំណើរការនីតិវិធីនៅ អ.វ.ត.ក ជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិមានអ្នកតំណាងដែលជាមេធាវីជាតិ ឬមេធាវីអន្តរជាតិដែលត្រូវសហការជាមួយមេធាវីជាតិ។

៤.២ អង្គភាពជនរងគ្រោះត្រូវមានបញ្ជីមេធាវីជាតិ និង អន្តរជាតិដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយជាមេធាវីដែលអាចធ្វើជាតំណាងអោយជនរងគ្រោះ ។

៤.៣ ប្រសិនបើជនរងគ្រោះជ្រើសរើសមេធាវីអន្តរជាតិ មេធាវីអន្តរជាតិនោះត្រូវតែសហការជាមួយមេធាវីជាតិនៅចំពោះមុខ អ.វ.ត.ក។

៤.៤ ក្រុមដើមបណ្តឹងរដ្ឋប្បវេណី អាចជ្រើសរើសមេធាវីតំណាងរួម ពីបញ្ជីមេធាវីនៃអង្គភាពជនរង-គ្រោះ។ អង្គភាពជនរងគ្រោះអាចជួយក្នុងការរៀបចំអោយមានមេធាវីតំណាងរួមគ្នានេះ ។ ក្នុងករណីចាំបាច់ ចៅក្រមអាចតំរូវអោយក្រុមដើមបណ្តឹងរដ្ឋប្បវេណីធ្វើការជ្រើសរើសមេធាវីតំណាងរួម ឬជ្រើសតាំងមេធាវីតំណាងនោះដោយខ្លួនឯង ។

**មាត្រា ៥.សមាគមជនរងគ្រោះ**

៥.១ សមាគមជនរងគ្រោះអាចជួយដើមបណ្តឹងរដ្ឋប្បវេណី តែសមាគមជនរងគ្រោះនោះមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេនៅក្នុងនីតិវិធី ។ ពួកគេគ្រាន់តែជាអ្នកតំណាងអោយសមាជិករបស់ខ្លួន ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ។ អាស្រ័យហេតុនេះ សមាជិកណាមួយនៃសមាគមជនរងគ្រោះ ត្រូវផ្តល់ព័ត៌មានផ្ទាល់ខ្លួន នៅក្នុងពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ។ ប៉ុន្តែពួកគេអាចស្នើសុំអោយសហចៅក្រមស៊ើបអង្កេតផ្តល់វិធានការការពារព័ត៌មានទាំងនោះ ។

៥.២ ដើម្បីអនុញ្ញាតអោយសមាគមជនគ្រោះ ធ្វើក្នុងនាមជនរងគ្រោះដែលជាសមាជិកបាន លុះណាតែសមាគមជនរងគ្រោះនោះ បានចុះបញ្ជីសមាគមនៅអង្គភាពជនរងគ្រោះ ដើម្បីធ្វើជាតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីនៃ អ.វ.ត.ក ដែលបញ្ជីនេះត្រូវបានកំណត់ឡើងដោយអង្គភាពជនរងគ្រោះ ស្ថិតនៅក្រោមការត្រួតពិនិត្យដោយសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង។

៥.៣ ទំរង់ពាក្យស្នើសុំដើម្បីចុះក្នុងបញ្ជីសមាគមជនរងគ្រោះដែលទទួលបានការអនុញ្ញាត អាចរកបាននៅអង្គភាពជនរងគ្រោះ ហើយអាចរកបាននៅលើគេហទំព័រ អ.វ.ត.ក ដែរ។

៥.៤ អង្គភាពជនរងគ្រោះនឹងផ្តល់ទៅអោយជនរងគ្រោះ នូវបញ្ជីនៃសមាគមជនរងគ្រោះ ដែលត្រូវបានអនុញ្ញាតអោយធ្វើជាតំណាងជនរងគ្រោះ ។

៥.៥ ដើម្បីអាចទទួលបានការអនុញ្ញាតចុះក្នុងបញ្ជីសមាគមជនរងគ្រោះ សមាគមជនរងគ្រោះត្រូវផ្តល់ទៅអង្គភាពជនរងគ្រោះ នូវឯកសារដែរបង្ហាញថាសមាគមនោះបានចុះបញ្ជីត្រឹមត្រូវ ឬ បានត្រូវបង្កើតនៅក្នុងប្រទេសណាមួយ ដែលសមាគមនោះធ្វើប្រតិបត្តិការ ។

៥.៦ សមាគមជនរងគ្រោះដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ត្រូវចុះបញ្ជីទៅតាមនីតិវិធីដែលមានជាធរមាន។ សំរាប់ព័ត៌មានពិស្តារបន្ថែម សូមធ្វើការទំនាក់ទំនងអាសយដ្ឋានដូចខាងក្រោមៈ

ក្រសួងមហាផ្ទៃ

អាសយដ្ឋាន: អគារលេខ ២៧៥ មហាវិថីនរោត្តម ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: ៨៥៥-២៣-៧៥០-៨០២/១២១-៧០៧/៧២៦-១៤៨

លេខទូរសារ: ៨៥៥-២៣-២១២-៧០៨/៧២៦-០៥២

អ៊ីម៉ែល: moi@interior.gov.kh , គេហទំព័រអាសយដ្ឋាន: www.interior.gov.kh

៥.៧ សមាគមជនរងគ្រោះបរទេសដែលតំណាងអោយជនរងគ្រោះ ដែលមានទីលំនៅនៅបរទេស នៅចំពោះមុខអ.វ.ត.ក មិនត្រូវបានបកស្រាយថាធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ ។

៥.៨ សមាគមជនរងគ្រោះត្រូវបង្ហាញភស្តុតាងថា ខ្លួនត្រូវបានអនុញ្ញាតអោយធ្វើជាអ្នកតំណាងជនរងគ្រោះ ដែលជាសមាជិកនៃសមាគមខ្លួន នៅក្នុងដំណើរការនីតិវិធីនៃអ.វ.ត.ក ។

៥.៩ សមាគមជនរងគ្រោះទាំងអស់អាចត្រូវបានតំណាងដោយមេធាវី ទៅតាមនីតិវិធីពិស្តារនៅក្នុងមាត្រា៤ខាងលើ ។

៥.១០ សមាគមជនរងគ្រោះទាំងអស់ មានសិទ្ធិប្តឹងឧទ្ធរណ៍លើសេចក្តីសំរេចដែលទាក់ទងទៅនឹងពាក្យស្នើសុំចុះបញ្ជីសមាគមជនរងគ្រោះនៅក្នុងអង្គភាពជនរងគ្រោះ ទៅអង្គបុរេជំនុំជម្រះ ។

៥.១១ នៅក្នុងករណីដែលមានការបដិសេធ ឬមិនមានសេចក្តីសំរេចនៃអង្គភាពជនរងគ្រោះ សមាគមជនរងគ្រោះអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល១៥ថ្ងៃ (ដប់ប្រាំ)គិតពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីចិត្តរបស់ប្រធានអង្គភាពជនរងគ្រោះ ឬនៅបញ្ចប់នៃរយៈពេល ៣០ថ្ងៃ (សាមសិប) ទៅតាមករណីសមស្រប ។

៥.១២ បើទោះបីជាមានជនរងគ្រោះមួយចំនួនជ្រើសរើសវិធីចូលរួមតាមរយៈសមាគមជនរងគ្រោះក៏ដោយ វាមិនប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះដទៃទៀត ក្នុងការចូលរួមជាភាគីរដ្ឋប្បវេណី នៅក្នុងសំណុំរឿងដូចគ្នានោះទេ ។

## មាត្រា ៦.ការដាក់ និង ការជូនដំណឹងអំពីឯកសារ

៦.១ នៅពេលដែលពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលហើយ រាល់ការដាក់ឯកសារ និងការជូនដំណឹងអំពីឯកសារដែលទាក់ទងទៅនឹងសំណុំរឿងនោះត្រូវតែធ្វើឡើងជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធ តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ដែលធ្វើចំណាត់ការលើសំណុំរឿងនោះ ដោយអនុលោមទៅតាមសេចក្តីណែនាំអនុវត្ត ក្នុងការដាក់ឯកសារនៅអ.វ.ត.ក ។

៦.២ ជនរងគ្រោះ មេធាវីជនរងគ្រោះ និង សមាគមនជនរងគ្រោះមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានអំពីអាសយដ្ឋាននៅក្នុងប្រទេសកម្ពុជា សំរាប់គោលបំណងក្នុងមាត្រានេះ។

វិសោធនកម្មថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens


*ឧបសម្ព័ន្ធ “ក” /វ០១*

# ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ

## ផ្នែក “ក”

**ព័ត៌មានផ្ទាល់ខ្លួននៃជនរងគ្រោះ**

| | |
|---|---|
| ១. នាមត្រកូល និងនាមខ្លួន: | |
| ១.១ នាមត្រកូល និងនាមខ្លួន ជាអក្សរឡាតាំង: | |
| ២. ឈ្មោះផ្សេងទៀត: | |
| ២.១ ឈ្មោះផ្សេងទៀត ជាអក្សរឡាតាំង: | |
| ៣. ភេទ ☐ ប្រុស ☐ ស្រី | ៤. ទីកន្លែងកំណើត: |
| ៥. អាយុ/ថ្ងៃខែឆ្នាំកំណើត (ថថ/ខខ/ឆឆឆឆ):<br>☐ចូរគូសក្នុងប្រអប់នេះប្រសិនបើថ្ងៃខែឆ្នាំកំណើតខុសពីឯកសារបញ្ជាក់អត្តសញ្ញាណ | ៦. ស្ថានភាពគ្រួសារ<br>☐ នៅលីវ ☐ រៀបការ ☐ លែងលះ<br>☐ ពោះម៉ាយ/មេម៉ាយ ☐ ផ្សេងៗ |
| ៧. សញ្ជាតិ: | ៨. មុខរបរ: |
| ៩. ឈ្មោះឪពុក ឬអាណាព្យាបាល: | ៩.១.ឈ្មោះឪពុកឬអាណាព្យាបាលជាអក្សរឡាតាំង: |
| ១០. ឈ្មោះម្តាយ: | ១០.១. ឈ្មោះម្តាយជាអក្សរឡាតាំង: |
| ១១. តើមានអ្នកនៅក្នុងបន្ទុកចំនួនប៉ុន្មាននាក់? *សូមសរសេរជាលេខ* | |
| ១២. តើអ្នកធ្លាប់មានពិការភាពពីមុនឬទេ? ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើឆ្លើយថា បាទ/ចាស សូមរៀបរាប់លំអិត: | |

១៣. តើឯកសារបញ្ជាក់អត្តសញ្ញាណខាងក្រោមណាមួយដែលអ្នកមាន? *សូមបញ្ជាក់ជាលេខ និងភ្ជាប់ច្បាប់ថតចម្លងមកជាមួយផង។*

| **ប្រភេទនៃភស្តុតាងនៃអត្តសញ្ញាណ** | **លេខ និង យោងផ្សេងៗ** |
|---|---|
| ☐ អត្តសញ្ញាណប័ណ្ណ (ដូចជាកាតសំគាល់និស្សិត, បុគ្គលិក) | |
| ☐ ប័ណ្ណបោះឆ្នោត | |
| ☐ លិខិតបញ្ជាក់ពីអាជ្ញាធរដែនដី | |
| ☐ ប័ណ្ណបើកបររថយន្ត | |
| ☐ លិខិតឆ្លងដែន | |
| ☐ លិខិតចុះឈ្មោះនៅក្នុងជំរំ | |
| ☐ ឯកសារពន្ធ | |
| ☐ កាតសំគាល់ចេញដោយអង្គការមនុស្សធម៌(ដូចជា UNHCR, WFP) | |
| ☐ ផ្សេងៗ | |
| ☐ គ្មាន | |

**១៤. អាសយដ្ឋានផ្ទាល់ខ្លួន**

១៤.១. ទីលំនៅអចិន្ត្រៃយ៍ *ប្រសិនបើអ្នកមិនមានអាសយដ្ឋានពិតប្រាកដ សូមផ្តល់នូវអាសយដ្ឋានចុងក្រោយ*

| | |
|---|---|
| លេខ/ប្លុក: | ផ្លូវ: |
| ក្រុម/ភូមិ: | ឃុំ/សង្កាត់: |
| ស្រុក/ខណ្ឌ: | ខេត្ត/ក្រុង: |

ប្រទេស:

១៤.២. អាសយដ្ឋានបច្ចុប្បន្ន (*ប្រសិនបើដូចទៅនឹងអាសយដ្ឋានអចិន្ត្រៃយ៍ មិនចាំបាច់បំពេញក្នុងប្រអប់ខាងក្រោមនេះទេ។*)

| | |
|---|---|
| លេខ/ប្លុក: | ផ្លូវ: |
| ក្រុម/ភូមិ: | ឃុំ/សង្កាត់: |
| ស្រុក/ខណ្ឌ: | ខេត្ត/ក្រុង: |

ប្រទេស:

១៤.៣ ទូរស័ព្ទសំរាប់ទំនាក់ទំនង:

☐ ផ្ទាល់ខ្លួន ឬ ☐ អ្នកដទៃ (*ចូរផ្តល់ឈ្មោះ*)

១៤.៤ សារអេឡិចត្រូនិចផ្ទាល់ខ្លួន (E-mail):

**១៥. មធ្យោបាយសំរាប់ទំនាក់ទំនង** *សូមគូសទៅតាមភាពសមស្រប*

ខ្ញុំចង់អោយទាក់ទងទៅតាមអាសយដ្ឋានដូចមាននៅក្នុងចំនុចលេខ១៤.១ ☐ ឬតាមអាសយដ្ឋានដូចមាននៅក្នុងចំនុចលេខ១៤.២ ☐
*ប្រសិនបើគូសក្នុងប្រអប់នេះសូមកុំបំពេញក្នុងប្រអប់ខាងក្រោម*

ខ្ញុំចង់អោយទាក់ទងទៅតាម:

☐ អង្គការអន្តរការី:

☐ សមាគមជនរងគ្រោះ:

☐ បុគ្គលដែលតំណាង:

☐ មេធាវី:

មេធាវីជាតិឈ្មោះ: មេធាវីអន្តរជាតិឈ្មោះ:

១៥.១ អាសយដ្ឋាន

| | |
|---|---|
| លេខ/ប្លុក: | ផ្លូវ: |
| ក្រុម/ភូមិ: | ឃុំ/សង្កាត់: |

| ស្រុក/ខណ្ឌ: | ខេត្ត/ក្រុង: |
| --- | --- |
| ប្រទេស: | |
| ទូរស័ព្ទលេខ: | |
| ហ្វាក់លេខ: | |
| សារអេឡិចត្រូនិច (E-mail): | |

**១៦. តើអ្នកធ្លាប់ដាក់ពាក្យប្តឹង ឬ ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅ អ.វ.ត.ក ពីមុនដែរឬទេ?**

☐ បាទ/ចាស ☐ ទេ

ប្រសិនបើឆ្លើយថា បាទ/ចាស ចូរបញ្ជាក់អំពីលេខចុះបញ្ជីរបស់អង្គភាពជនរងគ្រោះ ទម្រង់នៃការចូលរួមលើកមុន ពេលវេលា និងទីកន្លែងដាក់បញ្ជូនទម្រង់បែបបទ និងហេតុផលនៃការដាក់ទម្រង់បែបបទសាជាថ្មី។

លេខចុះបញ្ជី (ប្រសិនបើមាន):

ទម្រង់នៃការចូលរួម:

ទីកន្លែង: ថ្ងៃ ខែ ឆ្នាំ

និងហេតុផលនៃការដាក់ដាក់ទម្រង់បែបបទសាជាថ្មី:

## <u>ផ្នែក “ខ”</u>

**ព័ត៌មានទាក់ទងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់**

*សូមភ្ជាប់នូវចំលើយទាក់ទងនឹងផ្នែកនេះដោយក្រដាសដាច់ដោយឡែកប្រសិនបើចាំបាច់*

| |
| --- |
| ១. សូមផ្តល់នូវព័ត៌មានពិស្តារអំពីឧក្រិដ្ឋកម្ម |
| ទីកន្លែង (*ភូមិ, ស្រុក ,តំបន់, ភូមិភាគ)*: |
| កាលបរិច្ឆេទ (ថថ/ខខ/ឆឆឆឆ): |
| ការពិពណ៌នាអំពីឧក្រិដ្ឋកម្ម*(តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើង ហើយកើតឡើងដោយរបៀបណា?)*: |
| ២. តើអ្នកណាដែលអ្នកជឿជាក់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ហើយមូលហេតុអ្វីដែលអ្នកជឿជាក់បែបនេះ?<br>*សូមឆ្លើយសំណួរនេះទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន* |

| |
|---|
| ៣. តើអ្នកជាជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ |
| ៣.១. តើអ្នកបានដឹងអំពីជនរងគ្រោះផ្សេងទៀតនៃឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ<br>*(ប្រសិនបើឆ្លើយថាបាទ/ចាស (និងប្រសិនបើអ្នកមានលទ្ធភាព), សូមផ្តល់ឈ្មោះនិងអាសយដ្ឋានរបស់ពួកគេ, លើកលែងតែអ្នកដឹងថាពួកគេចង់នៅជាអនាមឹក, ឬវាអាចធ្វើអោយមានហានិភ័យចំពោះអ្នក ឬអ្នកណាផ្សេងទៀត):* |
| ៣.២. តើអ្នកមានទំនាក់ទំនងអ្វីជាមួយជនរងគ្រោះទាំងនោះ(ជាក្រុមគ្រួសារ, អ្នកជិតខាង, មិត្តភក្តិ, ។ល។)? ☐ បាទ/ចាស ☐ ទេ<br>*(ប្រសិនបើឆ្លើយថាបាទ/ចាស, សូមបញ្ជាក់):* |
| ៤. តើអ្នកជាសាក្សីនៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ |
| ៤.១. តើអ្នកបានដឹងអំពីសាក្សីផ្សេងទៀតនៃឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ<br>*(ប្រសិនបើឆ្លើយថាបាទ/ចាស (និងប្រសិនបើអ្នកមានលទ្ធភាព), សូមផ្តល់ឈ្មោះនិងអាសយដ្ឋានរបស់ពួកគេ, លើកលែងតែអ្នកដឹងថាពួកគេចង់រក្សាភាពអនាមឹក, ឬវាអាចធ្វើអោយមានភាពគ្រោះថ្នាក់ចំពោះអ្នក ឬអ្នកណាផ្សេងទៀត)* |
| ៤.២. តើអ្នកមានទំនាក់ទំនងអ្វីជាមួយសាក្សីទាំងនោះ(ជាក្រុមគ្រួសារ, អ្នកជិតខាង, មិត្តភក្តិ, ។ល។)? ☐ បាទ/ចាស ☐ ទេ<br>*(ប្រសិនបើឆ្លើយថាបាទ/ចាស, សូមបញ្ជាក់):* |
| **៥-សុវត្ថិភាព:** តើអ្នកមានការព្រួយបារម្ភអំពីផលវិបាកណាមួយចំពោះខ្លួនអ្នក ឬអ្នកណាផ្សេងទៀតមានឈ្មោះក្នុងទំរង់បែបបទនេះ ដែលបណ្តាលមកពីការដាក់ និងបញ្ជូនទំរង់បែបបទនេះទៅកាន់ អ.វ.ត.ក ដែរឬទេ? ☐ បាទ ☐ ចាស<br>បើមានការព្រួយបារម្ភ សូមពន្យល់ឲ្យបានច្បាស់លាស់: |

## <u>ផ្នែក “គ”</u>

### ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

| |
|---|
| *អ្នកត្រូវបំពេញក្នុងផ្នែកនេះ ប្រសិនបើអ្នកមានបំណងចង់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការស៊ើបសួរ* |
| ដើម្បីអោយតុលាការទទួលស្គាល់អ្នកជាដើមបណ្តឹងរដ្ឋប្បវេណី, ព្យសនកម្មត្រូវតែជា ក) រូបកាយ, សម្ភារៈ ឬ ផ្លូវចិត្ត; ខ) ប៉ះពាល់ដោយផ្ទាល់ពីបទល្មើសនោះជាលក្ខណៈបុគ្គល និងមានឥទ្ធិពលរហូតមកដល់ពេលបច្ចុប្បន្ន។ |
| ១. សូមបញ្ជាក់អំពីដំណាក់កាលនីតិវិធីដែលអ្នកមានបំណងចង់ចូលរួម<br>សំណុំរឿងលេខ: |
| ២. សូមបញ្ជាក់អំពីព្យសនកម្ម, ការបាត់បង់ឬ ផលវិបាកដែលបានទទួល និង សូមធ្វើការអត្ថាធិប្បាយដោយសង្ខេប<br>(ដូចជាព្យសនកម្មនៅលើរូបកាយ, ផ្លូវចិត្ត និងភាពតានតឹងនៅក្នុងចិត្ត, បាត់បង់ ឬខូចខាតនូវទ្រព្យសម្បត្តិ): |
| ៣. តើអ្នកត្រូវបានវេជ្ជបណ្ឌិតពិនិត្យក្រោយពីព្រឹត្តការណ៍នោះកើតឡើងឬទេ? ☐ បាទ/ចាស ☐ ទេ |

៤. តើអ្នកបានព្យាបាលដោយប្រើប្រាស់ថ្នាំ ឬដោយវិធីព្យាបាលផ្លូវចិត្តដែរឬទេ? ☐ បាទ/ចាស ☐ ទេ

៥. ប្រសិនបើបាទ/ចាស តើអ្នកមានកំណត់ត្រាអំពីការប្រើប្រាស់ថ្នាំ ឬដោយវិធីព្យាបាលផ្លូវចិត្តទាំងនោះដែរឬទេ?

☐ បាទ/ចាស ☐ ទេ

*ប្រសិនបើឆ្លើយថាបាទ/ចាស, សូមគូសទៅតាមភាពសមស្របខាងក្រោម និងផ្តល់ឯកសារចំលងមួយច្បាប់ប្រសិនបើអាច.*

☐ របាយការណ៍វេជ្ជបណ្ឌិត, មន្ទីរពេទ្យ, ឬមណ្ឌលសុខភាព ☐ កម្មរស្មី X ☐ វេជ្ជបញ្ជា/វិកិយប័ត្រថ្នាំ

☐ ផ្សេងៗ សូមបញ្ជាក់ ☐ មិនមានអ្វីទាំងអស់ដូចខាងលើ

៦. តើស្ថានភាពនៃព្យសនកម្មនោះមានរហូតមកដល់សព្វថ្ងៃដែរឬទេ? ☐ បាទ/ចាស ☐ ទេ

*ប្រសិនបើឆ្លើយបាទ/ចាស សូមបញ្ជាក់អោយបានពិស្តារ:*

៧.ដោយគោរពទៅលើការបាត់បង់ទ្រព្យសម្បត្តិ សូមផ្តល់ព័ត៌មានលំអិត ឬឯកសារជាក់ស្តែងដែលបញ្ជាក់ពីការកើតមាននូវការបាត់បង់ទ្រព្យសម្បត្តិនោះ:

៨. តើអ្នកមានបំណងចងទាមទារអោយមានសំណងជាលក្ខណ:សមូហភាព ឬជាផ្លូវចិត្តណាមួយដែរឬទេ? ☐ បាទ/ចាស ☐ ទេ

*ប្រសិនបើឆ្លើយបាទ/ចាស សូមបញ្ជាក់អោយបានពិស្តារ:*

## ផ្នែក “ឃ”

### ហត្ថលេខា

១. ហត្ថលេខាជនរងគ្រោះ

*សូមមេត្តាចុះហត្ថលេខា ឬផ្តិតស្រាមដៃ និងចុះកាលបរិច្ឆេទនៅលើបែបបទនេះ ទោះបីជានរណាម្នាក់ធ្វើក្នុងនាមរបស់អ្នក ឬ មាននរណាម្នាក់ជួយអ្នកក្នុងការបំពេញទម្រង់បែបបទនេះ*

ខ្ញុំសូមបញ្ជាក់ថា:

- ព័ត៌មានទាំងអស់ដែលបានផ្តល់ក្នុងបែបបទនេះពិតជាត្រឹមត្រូវពិតប្រាកដមែន ប្រសិនបើមានចំនុចណាមិនពិត ខ្ញុំសូមទទួលទោសតាមច្បាប់ជាធរមាន
- ខ្ញុំមានបំណងចង់ចូលរួមក្នុងនីតិវិធីនៅចំពោះមុខអ.វ.ត.ក ដោយដាក់ជូននូវទម្រង់បែបបទនេះជា **ពាក្យបណ្តឹង។**

☐ បន្ថែមលើការដាក់ជូននូវពាក្យបណ្តឹងនេះ ខ្ញុំក៏មានបំណងចង់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

*ប្រសិនបើចង់តាំងខ្លួនជា “ដើមបណ្តឹងរដ្ឋប្បវេណី” សូមប្រាកដអោយច្បាស់ថា ផ្នែក “គ” ត្រូវបានបំពេញ។*

ទីកន្លែងធ្វើ: ថ្ងៃ: ខែ: ឆ្នាំ:

.................................................................... ....................................................................

ហត្ថលេខា ឬស្នាមម្រាមដៃរបស់សាក្សី ហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនរងគ្រោះ

២.ហត្ថលេខាបុគ្គលដែលជាអ្នកតំណាងអោយជនរងគ្រោះដោយមានការយល់ព្រមពីជនរងគ្រោះ

ខ្ញុំ ..........................................................................................(ដាក់ឈ្មោះរបស់ជនរងគ្រោះ) យល់ព្រមអោយឈ្មោះ ........................................................................(ដាក់ឈ្មោះរបស់ជនដែលតំណាង) ដែលត្រូវជា......................... ...........................................................*(ទំនាក់ទំនងរវាងបុគ្គលជាតំណាង និងជនរងគ្រោះ)* អោយបំពេញ និងដាក់ទម្រង់បែបបទនេះតំណាងឱ្យខ្ញុំ។

ទីកន្លែងធ្វើ: ថ្ងៃ: ខែ: ឆ្នាំ:

................................................................................ ..........................................................

ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលតំណាង ហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនរងគ្រោះ

នៅមុនពេលដាក់បែបបទពាក្យស្នើសុំនេះ, សូមពិនិត្យមើលឡើងវិញ និងគូសនៅខាងក្រោមនេះទៅតាមការសមស្រប:

☐ ខ្ញុំបានភ្ជាប់មកជាមួយក្នុងពាក្យសុំនេះនូវឯកសារដូចខាងក្រោម:

១.

២.

៣.

☐ ខ្ញុំបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃនៅគ្រប់ទំព័រនៃបែបបទ និង ឯកសារដែលបានដាក់ភ្ជាប់មកជាមួយ

សូមបញ្ជាក់អំពីចំនួនទំព័រសរុបនៃទំព័ររបស់បែបបទនេះរួមទាំងទំព័របន្ថែម និងឯកសារភ្ជាប់ផ្សេងៗទៀត:

| **ជនរងគ្រោះ:** | **បុគ្គលតំណាងអោយជនរងគ្រោះ:** |
|---|---|
| ☐ ខ្ញុំបានផ្ដល់សេចក្ដីចំលងឯកសារជាភស្តុតាងនៃអត្តសញ្ញាណឆ្លើយតបទៅនឹងតំរូវការនៅក្នុងសំនួរទី១៣នៃផ្នែក “ក” ។<br>☐ ខ្ញុំបានផ្ដល់ព័ត៌មានឆ្លើយតបនឹងតំរូវការនៅក្នុងសំនួរទី១៤ និង១៥ នៃផ្នែក “ក” ។<br>☐ ខ្ញុំបានចុះហត្ថលេខា ឬផ្ដិតម្រាមនៅក្នុងប្រអប់ទី១នៅក្នុងផ្នែក “ឃ” ។ | ☐ ខ្ញុំបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃនៅក្នុងប្រអប់ទីពីរនៅក្នុងផ្នែក “ឃ”។ |

**កំណត់ចំណាំ**

នៅពេលដែល អ.វ.ត.ក ទទួលបែបបទនេះ អ្នកនឹងទទួលបាននូវការបញ្ជាក់ ។ ការបញ្ជាក់នេះនឹងផ្ដល់ទៅអ្នកជាមួយនឹងលេខដែលបានចុះបញ្ជីដែលអ្នកត្រូវប្រើនៅក្នុងការទំនាក់ទំនងជាមួយតុលាការ ។ ប្រសិនបើអ្នកផ្ដល់ព័ត៌មានបន្ថែមមកតុលាការ សូមប្រើប្រាស់លេខដែលបានផ្ដល់អោយនេះ ដើម្បីអោយគេអាចបន្ថែមនៅលើពាក្យស្នើសុំរបស់អ្នក ។ សូមបញ្ជាក់ថាដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវការប្រើប្រាស់ពេលវេលវែង និងអ.វ.ត.ក អាចត្រូវការប្រើប្រាស់ពេលវេលាមួយដើម្បីធ្វើការសំរេចលើពាក្យស្នើសុំ ។

ការដាក់បែបបទនេះគឺធ្វើឡើងដោយមិនមានគិតថ្លៃ ។ អង្គភាពជនរងគ្រោះអាចទំនាក់ទំនងបានតាមរយៈអាសយដ្ឋានខាងក្រោម ឬតាមរយៈអ៊ីម៉ែល victimsunit@eccc.gov.kh ។